# មេរៀនទី ១ ៖ ការរៀបចំ និងការដឹកនាំការប្រជុំ

*អ្នកអាចបង្រៀនមេរៀននេះម្ដងទាំងអស់ ឬបំបែកវាជាផ្នែកខ្លីៗជាងនេះ ។ សូមសម្របមេរៀននេះតាមកាលៈទេសៈក្នុងមូលដ្ឋានរបស់អ្នក និងតាមតម្រូវការ តាមអាយុ ព្រមទាំងតាមការយល់ដឹងរបស់គណៈប្រធានកូរ៉ុម ឬថ្នាក់របស់អ្នក ។*

## ព្រះអម្ចាស់អញ្ជើញយើងឲ្យរៀបចំខ្លួនយើង

សូមអាន គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:១១៩ ។ សូមពិភាក្សាពីរបៀបដែលការណែនាំរបស់ព្រះអម្ចាស់ឲ្យ « រៀបចំខ្លួន » អនុវត្តចំពោះការប្រជុំគណៈប្រធានកូរ៉ុម និងថ្នាក់រៀន ។ តើមានអ្វីខ្លះដែលយើងអាចធ្វើបានដើម្បីរៀបចំការប្រជុំរបស់យើង ?

## ការដាក់ផែនការសម្រាប់ការប្រជុំជួយយើងឲ្យរៀបចំកិច្ចការរបស់ព្រះអម្ចាស់

សូមជួយគណៈប្រធានកូរ៉ុម ឬថ្នាក់រៀនឲ្យបំពេញ របៀបវារៈគំរូ ជាការរៀបចំសម្រាប់ការប្រជុំគណៈប្រធានលើកក្រោយរបស់ពួកគេ ។ សូមពិចារណាពិភាក្សាសំណួរដូចតទៅនេះជាមួយគ្នា ៖

- ហេតុអ្វីវាសំខាន់ដើម្បីពិចារណាពីសំណួរដូចជាសំណួរនៅលើរបៀបវារៈគំរូនេះ ?
- តើយើងអាចរៀបចំតាមរបៀបនេះសម្រាប់ការប្រជុំ ឬសកម្មភាពផ្សេងទៀតណាខ្លះ ?
- តើយើងអាចយាងព្រះវិញ្ញាណបរិសុទ្ធឲ្យជួយយើង កាលយើងរៀបចំ និងដឹកនាំការប្រជុំដោយរបៀបណា ? ( សូមមើល ម៉ូរ៉ូណៃ ៦:៩; គោលលទ្ធិ និង សេចក្ដីសញ្ញា ៤៦:២ ) ។

អ្នកក៏អាចអញ្ជើញសមាជិកគណៈប្រធានឲ្យរៀបចំរបៀបវារៈមួយសម្រាប់ការប្រជុំកូរ៉ុម ឬថ្នាក់រៀនលើកក្រោយផងដែរ ដែលវាធ្វើតាមគម្រោងដែលបានផ្ដល់នៅក្នុងមេរៀនទីមួយ។ក្នុង *ចូរមកតាមខ្ញុំ—សម្រាប់កូរ៉ុមបព្វជិតភាពអើរ៉ុន និងថ្នាក់យុវនារី* ។ សូមអញ្ជើញពួកគេឲ្យគិតអំពីចំណុចដែលបានពិភាក្សានៅក្នុងការប្រជុំគណៈប្រធានរបស់ពួកគេ ដែលត្រូវពិភាក្សាជាមួយនឹងសមាជិកកូរ៉ុម និងថ្នាក់រៀនផងដែរ ។ ប្រសិនបើមានពេល អ្នកអាចអញ្ជើញពួកគេឲ្យរៀនដឹកនាំការប្រជុំមួយ ដោយប្រើរបៀបវារៈដែលពួកគេបានរៀបចំ ។

ម្ដងម្កាល អ្នកអាចពិភាក្សាពីអារម្មណ៍របស់សមាជិកគណៈប្រធានអំពីការប្រជុំ ។ ជាផ្នែកមួយនៃការពិភាក្សានេះ អ្នកអាចសួរសំណួរដូចតទៅនេះ ៖

- តើការប្រជុំនេះសម្រេចបានអ្វីដែលយើងបានគ្រោងទុកដែរឬទេ ?
- តើយើងអាចធ្វើអ្វីខ្លះដើម្បីយាងព្រះវិញ្ញាណឲ្យគង់នៅក្នុងការប្រជុំ ? ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:៣២ ) ។
- តើយើងបានព្យាយាមរួមបញ្ចូលមនុស្សគ្រប់គ្នាទេ ?
- តើយើងអាចកែលម្អដោយរបៀបណា ?

## ធនធានគាំទ្រ

- *គម្ពីរខ្នាតទូទៅ ៖ ការបម្រើនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ* ១០.៤, ១១.៣.៣, នៅលើគេហទំព័រ ChurchofJesusChrist.org

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២០ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២០ ។ ការបកប្រែនៃ Quorum and Class Presidency Training - Lesson ១. Cambodian.
PD60010736 258. បោះពុម្ពនៅសហរដ្ឋអាមេរិក